ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ក្រសួងសាធារណការនិងដឹកជញ្ជូន

លេខ : ១០០សហវ.ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០០៧

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការគ្រប់គ្រងរថយន្តចង្កូតស្តាំ ដែលមានស្រាប់នៅក្នុងប្រទេស

*** ៚ ***

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងសារាចរលេខ ០២ ស.រ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការអនុញ្ញាតឱ្យប្រើប្រាស់រថយន្តចង្កូតស្តាំដែលមានស្រាប់នៅក្នុងប្រទេស
- យោងចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ លើលិខិតលេខ ៧៨២២ សហវ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីករណីពាក់ព័ន្ធនឹងការប្រមូលពន្ធនិងអាករលើយានយន្តចង្កូតស្តាំគ្រប់ប្រភេទដែលកំពុងចរាចរនៅក្នុងស្រុក
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការនិងដឹកជញ្ជូន ⁄

**សំរេច**

**ប្រការ ១:** មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត- ក្រុង ព្រមទាំងអង្គភាពមានសមត្ថកិច្ចនៃក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវធ្វើការចុះបញ្ជីយានយន្ត និងផ្តល់ផ្លាកលេខរថយន្តចង្កូតស្តាំគ្រប់ប្រភេទ ដែលមានស្រាប់ក្នុងប្រទេស ហើយដែលបានបំពេញកាតព្វកិច្ចបង់ពន្ធត្រឹមត្រូវរួចហើយ ឱ្យមានសិទ្ធិធ្វើចរាចរដោយស្របច្បាប់លើផ្លូវសាធារណៈ។

**ប្រការ ២:** នីតិវិធីក្នុងការចេញផ្លាកលេខជូនរថយន្តចង្កូតស្តាំនេះ អនុវត្តចំពោះតែរថយន្តចង្កូតស្តាំទាំងឡាយណាដែលមានបង្កាន់ដៃពន្ធនាំចូលដែលមានការពិនិត្យ និងបញ្ជាក់ត្រឹមត្រូវពីទីចាត់ការគយនិងរដ្ឋាករ។ ក្នុងករណីដែលមន្ត្រីមានសមត្ថកិច្ចដូចរៀបរាប់ក្នុងប្រការ ១ ខាងលើ ពិនិត្យឃើញថា ការបង់ពន្ធយានយន្តណាមួយមានលក្ខណៈពុំត្រឹមត្រូវដោយប្រការណាមួយ ម្ចាស់យានយន្តទាំងនោះត្រូវចូលខ្លួនមកទីចាត់ការគយនិងរដ្ឋាករ ដើម្បីបំពេញកាតព្វកិច្ចបង់ពន្ធឱ្យបានត្រឹមត្រូវតាមការកំណត់ឡើងវិញ ចៀសវាងនូវការយឺតយ៉ាវជាយថាហេតុក្នុងការផ្តល់ផ្លាកលេខជូន។

**ប្រការ ៣:** ម្ចាស់រថយន្តចង្កូតស្តាំដែលមានស្រាប់នៅក្នុងប្រទេស ហើយពុំទាន់មានលទ្ធភាពបំពេញកាតព្វកិច្ចពន្ធ អាករនាំចូលនៅឡើយនោះ ត្រូវរួសរាន់ចូលខ្លួនមកប្រកាសចុះបញ្ជីយានយន្តចង្កូតស្តាំរបស់ខ្លួននៅតាមគ្រប់សាខា ការិយាល័យ ឬទីស្នាក់ការគយនិងរដ្ឋាករនៅទូទាំងប្រទេស ដែលនៅជិតលំនៅដ្ឋានរបស់ខ្លួនចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ រហូតដល់ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៧ ជាកំហិត។ ចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៧ ម្ចាស់យានយន្តចង្កូតស្តាំដែលមានស្រាប់នៅក្នុងប្រទេសទាំងអស់ អាចបំពេញកាតព្វកិច្ចពន្ធនៅការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធ តាមសាខាគយនិងរដ្ឋាករខេត្ត- ក្រុង និងនៅទីស្នាក់ការគយនិងរដ្ឋាករតាមខណ្ឌទាំងអស់របស់សាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ បានតែក្នុងករណីដែលរថយន្តចង្កូតស្តាំទាំងនោះមានចុះបញ្ជីរួចរាល់ប៉ុណ្ណោះ។

**ប្រការ ៤:** យានយន្តចង្កូតស្តាំទាំងឡាយណាដែលពុំបានចុះបញ្ជី ឬពុំបានបំពេញកាតព្វកិច្ចពន្ធតាមកាលកំណត់ខាងលើនេះ នឹងត្រូវចាត់ទុកជារថយន្តដែលនាំចូលក្រោយថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៦ រំលោភលើស្មារតីសារាចរលេខ ០២ សរ ដូចយោងខាងលើ និងមិនត្រូវបានអនុញ្ញាតឱ្យបំពេញកាតព្វកិច្ចពន្ធ អាករទៀតឡើយ ហើយត្រូវចាប់ឃាត់ជាបណ្តោះអាសន្ន និងបញ្ជូនករណីនេះទៅតុលាការមានសមត្ថកិច្ច ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

**ប្រការ ៥:** អគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការនិងដឹកជញ្ជូន និងទីចាត់ការគយនិងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកសាងចំណុចទំនាក់ទំនង (Focal Point) មួយដែលមានការចូលរួមពីមន្ត្រី ០៣(បី)រូប ពីស្ថាប័ននីមួយៗ ដើម្បីធ្វើការផ្លាស់ប្តូរពត៌មាន ឬដោះស្រាយបញ្ហាផ្សេងៗដែលកើតមានឡើងជាយថាហេតុ ក្នុងដំណើរការអនុវត្តប្រកាសអន្តរក្រសួងនេះ និង

សហការគ្នាឱ្យបានល្អ លុបបំបាត់នូវអំពើល្មើសអសកម្ម រំលោភបំពានលើការហាមឃាត់របស់រាជរដ្ឋាភិបាលកន្លងមក។

**ប្រការ ៦:** អគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការនិងដឹកជញ្ជូន ទីចាត់ការគយនិងរដ្ឋាករ និងនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់ចែងផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈនានាដល់មហាជនគ្រប់ស្រទាប់ឱ្យបានយល់ និងមានការទទួលខុសត្រូវខ្ពស់ចំពោះមុខច្បាប់ និងចូលរួមអនុវត្តតាមខ្លឹមសារប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ប្រការ ៧:** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ ប្រធាននាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូន នាយកមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត-ក្រុង និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ស៊ុន ចាន់ថុល

**ចម្លងជូន :**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់សាលាខេត្ត-ក្រុង
  "ដើម្បីជូនជ្រាប និងសុំកិច្ចសហការផ្សព្វផ្សាយ"
- គ្រប់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង
- គ្រប់សាខា ការិយាល័យ និងទីស្នាក់ការគយនិងរដ្ឋាករពាក់ព័ន្ធ
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ